LONG BEACH Utilities
Water · Gas · Sewer

# សេចក្ដីជូនដំណឹង
# របស់នាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិច អំពីទឹកឆ្អិន
# អនុវត្តពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០២៤

## សំណួរដែលបងប្អូនសួរញឹកញាប់៖

### សំណួរ1

**តើសេចក្ដីជូនដំណឹង អំពីទឹកអំពីទឹកឆ្អិននេះ ត្រូវអនុវត្តតាមដល់ពេលណាទើបឈប់?**

នាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិច កំពុងធ្វើតេស្តផ្នែកឯកទេសល្អិតល្អន់មួយ ដើម្បីពិនិត្យមើលគុណភាពទឹក។ ដូច្នេះ បងប្អូនប្រជាពលរដ្ឋទាំងអស់ នឹងត្រូវធ្វើតាមសេចក្ដីជូនដំណឹងអំពីទឹកឆ្អិននេះ រហូតដល់ខាងនាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិច អាចផ្ទៀងផ្ទាត់បាន ថាទឹកមានសុវត្ថិភាព ដើម្បីឲ្យបងប្អូនទទួលទានវិញបានដូចធម្មតា។ យើងខ្ញុំនឹងជូនដំណឹងថ្មីៗជាទៀងទាត់ ដើម្បីឲ្យបងប្អូនសហគមន៍បានជ្រួតជ្រាប។

### សំណួរ2

**តើខ្ញុំអាចងូតទឹកហ្នឹងបានដែរឬទេ?**

បាទ/ចាស! ងូតបាន។ ទឹកនេះមានសុវត្ថិភាពសម្រាប់ងូតបាន។

### សំណួរ3

**តើខ្ញុំអាចហូបទឹកចម្រោះពីទូទឹកកកបានដែរឬទេ?**

បាទ/ចាស! អាចហូបបាន។ ប៉ុន្តែ ទាល់តែបងប្អូនដាំវាឲ្យឆ្អិនសិន។

### សំណួរ4

**តើខ្ញុំត្រូវធ្វើយ៉ាងដូចម្ដេច**

- ដាំទឹកនោះឲ្យពុះមួយនាទី។
- ទុកវាឲ្យត្រជាក់ សូមពិសា។
- សូមប្រើទឹកដាំ ឬទឹកដប ដើម្បីពិសា ដុសធ្មេញ និងលាងសម្អាតបន្លែបង្ការ ឬចំណីអាហារ។ ត្រូវបន្តធ្វើដូច្នេះ រហូតមានសេចក្ដីជូនដំណឹងថ្មី។
- ទឹកដាំឆ្អិនសម្លាប់បាក់តេរី និងមេរោគដទៃទៀតដែលនៅក្នុងទឹក។

### សំណួរ5

**តើធ្វើដូចម្ដេចទើបខ្ញុំទទួលបានដំណឹងថ្មីៗភ្លាមៗ?**

សូមចុះឈ្មោះតាមតំណភ្ជាប់នេះ **AlertLB** ដើម្បីទទួលបានព័ត៌មានថ្មីៗ និងសារជូនដំណឹងបន្ទាន់ សម្រាប់ទីក្រុងឡុងប៊ិច។ សូមតាមដានយើងខ្ញុំតាមបណ្ដាញសង្គមហ្វេសប៊ុក, Instagram, និង X @LBUtilities។ បងប្អូនអាចទូរស័ព្ទមកយើងខ្ញុំតាមលេខទូរស័ព្ទនាយកដ្ឋានធនធានទឹកនេះ៖ 562-570-2390។

### សំណួរ6

**តើមានបញ្ហាអ្វីខ្លះ បើខ្ញុំបានជាជ្រុលហូបទឹកនោះទៅហើយ មុនឃើញសេចក្ដីជូនដំណឹងនេះ?**

សេចក្ដីជូនដំណឹងអំពីទឹកឆ្អិននេះ គឺជាវិធានការប្រុងប្រយ័ត្ន ដើម្បីធ្វើយ៉ាងណាឲ្យសហគមន៍យើងមានសុវត្ថិភាព។ រហូតមកដល់ពេលនេះ ពុំមានភស្តុតាងណាមួយបញ្ជាក់ ថាទឹកនោះមានបញ្ហានោះឡើយ។